## ពិរុទ្ធភាពត្រួតគ្នា (cumulative conviction)

ការអនុញ្ញាតឲ្យមានការចោទប្រកាន់ត្រួតគ្នា (cumulative charge) នាំឲ្យមានពិរុទ្ធភាពត្រួតគ្នា (cumulative conviction) និងទោសត្រួតគ្នា (cumulative sentence)។

ពិរុទ្ធភាពត្រួតគ្នាមិនខុសទេ ទោះបីបទល្មើស មានឈ្មោះដូចគ្នាក្ដី ឲ្យតែមានធាតុផ្សំបទល្មើសខុសគ្នាជាចម្បង។ ការខុសគ្នាជាចម្បងនេះ ស្ដែងតាមការទាមទារភស្តុតាងនៃអង្គហេតុ ដែលមិនត្រូវបានទាមទារដោយបទល្មើសផ្សេងទៀត (Akayesu, ICTR-96-4-T, 1998, S 468)។ ជាក់ស្ដែង ការសម្លាប់ដោយចេតនា (willful killing) ដែលជាការបំពានធ្ងន់ធ្ងរអនុសញ្ញាហ្សឺណែវ មានធាតុផ្សំខុសពីមនុស្សឃាត (murder) (រំលោភច្បាប់និងទំនៀមទម្លាប់ក្នុងសង្គ្រាម) ដោយសារ ជនរងគ្រោះត្រូវតែជាមនុស្សដែលត្រូវការពារ (protected person)។ ដូចគ្នានេះដែរ ការសម្លាប់រង្គាល (extermination) ខុសពីការសម្លាប់ក្នុងបទប្រល័យពូជសាសន៍ (genocide) ដែលបទល្មើសខាងក្រោយនេះ ទាមទារនូវចេតនាពិសេស (specific intent)។

ទោះបីជាការសម្លាប់ជាទង្វើមួយ នៃការធ្វើទុក្ខបុកម្នេញក្ដី ការចោទពីបទសម្លាប់និងធ្វើទុក្ខបុកម្នេញ (persecution) មិនខុសទេ ដោយសារ បទល្មើសខាងក្រោយ ទាមទារធាតុផ្សំរើសអើង (discrimination) (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 289-290)។